**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១៦ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៨៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលសមាសភាពនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំ ការសម្របសម្រួល និងការគ្រប់គ្រងកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការចំណុះគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តក្នុងក្របខ័ណ្ឌនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២

## អនុគណៈកម្មាធិការចំណុះ គ.ជ.អ.ប.

**មាត្រា ៤.-**

បង្កើតអនុគណៈកម្មាធិការនានាចំណុះ គ.ជ.អ.ប. ដូចខាងក្រោម៖

- **អនុគណៈកម្មាធិការមុខងារ និងធនធាន**
- **អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ**
- **អនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។**

**មាត្រា ៥.-**

អនុគណៈកម្មាធិការនីមួយៗមានសមាសភាពដូចខាងក្រោម៖

**១. អនុគណៈកម្មាធិការមុខងារ និងធនធាន**

| | |
|---|---|
| – រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ជាប្រធាន |
| – ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.អ.ប. | ជាអនុប្រធានអចិន្ត្រៃយ៍ |
| – រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ ១រូប | ជាអនុប្រធាន |
| – រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១រូប | ជាអនុប្រធាន |
| – រដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ ១រូប | ជាអនុប្រធាន |

- រដ្ឋលេខាធិការនៃក្រសួងកិច្ចការនារី ១រូប ជាអនុប្រធាន
- រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ១រូបនៃក្រសួងជាសមាជិក គ.ជ.អ.ប. ជាសមាជិក
- ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. ជាសមាជិក
- តំណាងសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ១រូប ជាសមាជិក
- តំណាងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ១រូប ជាសមាជិក។

**២. អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ**

- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន
- រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១រូប ជាអនុប្រធានអចិន្ត្រៃយ៍
- រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ ១រូប ជាអនុប្រធាន
- រដ្ឋលេខាធិការនៃក្រសួងផែនការ ១រូប ជាអនុប្រធាន
- រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ១រូបនៃក្រសួងជាសមាជិក គ.ជ.អ.ប. ជាសមាជិក
- ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. ជាសមាជិក
- តំណាងសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ១រូប ជាសមាជិក
- តំណាងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ១រូប ជាសមាជិក។

**៣. អនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ជាប្រធាន
- រដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ ១រូប ជាអនុប្រធានអចិន្ត្រៃយ៍
- រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ ១រូប ជាអនុប្រធាន
- រដ្ឋលេខាធិការនៃទីស្ដីការគណៈរដ្ឋមន្ត្រី ១រូប ជាអនុប្រធាន
- រដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា ១រូប ជាអនុប្រធាន
- រដ្ឋលេខាធិការនៃក្រសួងសុខាភិបាល ១រូប ជាអនុប្រធាន
- រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ១រូបនៃក្រសួងជាសមាជិក គ.ជ.អ.ប. ជាសមាជិក
- ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. ជាសមាជិក
- តំណាងសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ១រូប ជាសមាជិក
- តំណាងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ១រូប ជាសមាជិក។

**មាត្រា ៦.-**

រដ្ឋលេខាធិការដែលជាអនុប្រធានអចិន្ត្រៃយ៍ រដ្ឋលេខាធិការដែលជាអនុប្រធាន និងរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ និងតំណាងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដែលជាសមាជិកនៃអនុគណៈកម្មាធិការនីមួយៗ ត្រូវចាត់តាំងដោយរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី និងត្រូវទទួលស្គាល់ដោយ គ.ជ.អ.ប.។

## ជំពូកទី ៣
## តួនាទី ភារកិច្ចរបស់អនុគណៈកម្មាធិការ

**មាត្រា ៧.-**

**អនុគណៈកម្មាធិការមុខងារ និងធនធាន**មានតួនាទីផ្តល់យោបល់ជូន គ.ជ.អ.ប. លើកិច្ចការនានាពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងការអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងឯកសារបច្ចេកទេសនានាពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការសម្រុះសម្រួលដោះស្រាយវិវាទរដ្ឋបាល និងវិវាទមូលដ្ឋានក្រៅប្រព័ន្ធតុលាការក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការលើកកម្ពស់សមភាពយេនឌ័រ និងការបន្សាំការប្រែប្រួលអាកាសធាតុ
- ពិនិត្យ និងផ្តល់យោបល់លើជម្រើសនានាសម្រាប់ការរៀបចំ និងកែសម្រួលរចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិភាក្សា និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាដើម្បីកំណត់មុខងារ និងធនធាន បែបបទ និងនីតិវិធីសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើវិធានការ ឬវិធីសាស្ត្រពង្រឹង និងពង្រីកការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងកំណត់នូវជម្រើសសមស្របសម្រាប់ដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងការពង្រឹងយន្តការ និងនីតិវិធីសម្រាប់អនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ ការពង្រឹង និងការកែលម្អយន្តការ នីតិវិធី និងដំណើរការសម្រុះសម្រួលដោះស្រាយវិវាទរដ្ឋបាល និងវិវាទមូលដ្ឋានក្រៅប្រព័ន្ធតុលាការក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំយន្តការគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តមុខងារ និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការសម្រុះសម្រួលដោះស្រាយវិវាទរដ្ឋបាល និងវិវាទមូលដ្ឋានក្រៅប្រព័ន្ធតុលាការក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន
- បំពេញភារកិច្ចផ្សេងទៀតតាមការណែនាំរបស់ គ.ជ.អ.ប.។

**មាត្រា ៨.-**

**អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ**មានតួនាទីផ្តល់យោបល់ជូន គ.ជ.អ.ប. លើកិច្ចការនានាពាក់ព័ន្ធនឹងការធ្វើវិមជ្ឈការហិរញ្ញវត្ថុ ការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ព្រមទាំងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងការអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រថវិកា និងឯកសារបច្ចេកទេសនានាពាក់ព័ន្ធនឹងការធ្វើវិមជ្ឈការហិរញ្ញវត្ថុ ការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិភាក្សា និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាដើម្បីកំណត់នូវធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ បែបបទ និងនីតិវិធីសម្រាប់ផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ ធនធានហិរញ្ញវត្ថុគ្មានភ្ជាប់លក្ខខណ្ឌ ចំណូលចែករំលែក និងទ្រព្យសម្បត្តិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងការកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ប្រព័ន្ធ នីតិវិធី និងដំណើរការកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងជម្រើសនានាសម្រាប់ការបង្កើតប្រភពចំណូលផ្ទាល់នៅមូលដ្ឋាន និងការរៀបចំប្រព័ន្ធបែងចែកធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយសមធម៌
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងការកែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលដ្ឋាននានាសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំបន្សុីគ្នារវាងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគជាមួយនឹងដំណើរការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំស្តង់ដា និងបែបបទសម្រាប់ការធ្វើសវនកម្មផ្ទៃក្នុង និងផ្ទៃក្រៅលើការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំយន្តការគាំទ្រ អភិវឌ្ឍសមត្ថភាព តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បំពេញភារកិច្ចផ្សេងទៀតតាមការណែនាំរបស់ គ.ជ.អ.ប.។

**មាត្រា ៩.-**

**អនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**មានតួនាទីផ្តល់យោបល់ជូន គ.ជ.អ.ប. លើកិច្ចការនានាពាក់ព័ន្ធនឹងការរៀបចំ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងការអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋាន

គតិយុត្ត និងឯកសារបច្ចេកទេសនានាពាក់ព័ន្ធនឹងការរៀបចំ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ពិនិត្យ និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាដើម្បីកំណត់អំពីប្រភេទ ចំនួនបុគ្គលិក បែបបទ និងនីតិវិធីសម្រាប់ផ្ទេរបុគ្គលិកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងការកែលម្អប្រព័ន្ធគ្រប់គ្រងបុគ្គលិក ព្រមទាំងការរៀបចំការពិពណ៌នាមុខតំណែង និងលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងការពង្រឹងយន្តការអភិវឌ្ឍសមត្ថភាព ព្រមទាំងវិធីសាស្ត្រ និងកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងការដាក់ឱ្យអនុវត្តនូវប្រព័ន្ធវាយតម្លៃការបំពេញការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បំពេញភារកិច្ចផ្សេងទៀតតាមការណែនាំរបស់ គ.ជ.អ.ប.។

## ជំពូកទី ៤

## របៀបរបបការងាររបស់អនុគណៈកម្មាធិការ

**មាត្រា ១០.-**

អនុគណៈកម្មាធិការនីមួយៗត្រូវបំពេញការងារតាមការចាត់ចែងរបស់ប្រធានអនុគណៈកម្មាធិការ។

សមាជិកនៃអនុគណៈកម្មាធិការនីមួយៗត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានអនុគណៈកម្មាធិការ។

អនុប្រធានអចិន្ត្រៃយ៍នៃអនុគណៈកម្មាធិការត្រូវដឹកនាំកិច្ចប្រជុំជំនួសក្នុងពេលដែលប្រធានអនុគណៈកម្មាធិការអវត្តមាន ឬតាមការប្រគល់សិទ្ធិពីប្រធានអនុគណៈកម្មាធិការ។

**មាត្រា ១១.-**

អនុគណៈកម្មាធិការនីមួយៗត្រូវរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ ដើម្បីបូកសរុប និងត្រួតពិនិត្យលើការអនុវត្តការងាររបស់ខ្លួន និងអាចរៀបចំកិច្ចប្រជុំតាមការចាំបាច់។

សេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំរបស់អនុគណៈកម្មាធិការនីមួយៗ អាស្រ័យទៅលើការកំណត់របស់ប្រធានអនុគណៈកម្មាធិការ ឬផ្អែកលើសំណើរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ឬផ្អែកតាមការណែនាំរបស់ប្រធាន គ.ជ.អ.ប.។

កិច្ចប្រជុំអនុគណៈកម្មាធិការអាចយកជាការបាន លុះត្រាតែមានវត្តមានសមាជិកអនុគណៈកម្មាធិការចូលរួមកិច្ចប្រជុំលើសពីពាក់កណ្តាលនៃសមាជិកអនុគណៈកម្មាធិការទាំងមូល។

ក្នុងករណីពុំអាចចូលរួមកិច្ចប្រជុំបាន សមាជិកអនុគណៈកម្មាធិការនីមួយៗអាចចាត់តំណាងដែលមានសិទ្ធិសម្រេចឱ្យចូលរួមជំនួសក្នុងកិច្ចប្រជុំរបស់អនុគណៈកម្មាធិការ។

**មាត្រា ១២.-**

អនុគណៈកម្មាធិការនីមួយៗអាចអញ្ជើញមន្ត្រី ឬអ្នកពាក់ព័ន្ធនានាដើម្បីចូលរួមកិច្ចប្រជុំអនុគណៈកម្មាធិការតាមការចាំបាច់។

មន្ត្រី ឬអ្នកពាក់ព័ន្ធដែលចូលរួមកិច្ចប្រជុំខាងលើនេះ មានសិទ្ធិផ្តល់យោបល់ ប៉ុន្តែគ្មានសិទ្ធិសម្រេចលើកិច្ចការណាមួយរបស់អនុគណៈកម្មាធិការឡើយ។

**មាត្រា ១៣.-**

រាល់ការសម្រេចរបស់អនុគណៈកម្មាធិការក្នុងការផ្តល់យោបល់ ឬអនុសាសន៍នានាជូន គ.ជ.អ.ប. ត្រូវធ្វើឡើងដោយមានការឯកភាពគ្នាផ្អែកលើសំឡេងគាំទ្រភាគច្រើនដាច់ខាតនៃចំនួនសមាជិករបស់អនុគណៈកម្មាធិការដែលមានវត្តមានក្នុងកិច្ចប្រជុំ។

**មាត្រា ១៤.-**

រាល់កិច្ចប្រជុំទាំងអស់របស់អនុគណៈកម្មាធិការត្រូវមានកំណត់ហេតុកិច្ចប្រជុំដែលត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ។

អនុគណៈកម្មាធិការនីមួយៗត្រូវរៀបចំ និងផ្ញើរបាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំនីមួយៗជូនប្រធាន គ.ជ.អ.ប.។

**មាត្រា ១៥.-**

អនុគណៈកម្មាធិការនីមួយៗត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ ឬរបាយការណ៍តាមពេលវេលាជាក់លាក់ណាមួយដែលកំណត់ដោយ គ.ជ.អ.ប. ពាក់ព័ន្ធនឹងកិច្ចការដែលស្ថិតក្នុងវិសាលភាពនៃតួនាទី និងភារកិច្ចរបស់អនុគណៈកម្មាធិការជូន គ.ជ.អ.ប.។

**មាត្រា ១៦.-**

អនុគណៈកម្មាធិការនីមួយៗត្រូវប្រើប្រាស់ធនធានថវិកា ទ្រព្យសម្បត្តិ ឧបករណ៍ សម្ភារ បុគ្គលិក និងត្រារបស់ក្រសួងដែលរដ្ឋមន្ត្រីនៃក្រសួងនោះជាប្រធាននៃអនុគណៈកម្មាធិការនីមួយៗសម្រាប់ការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន។

**មាត្រា ១៧.-**

អនុគណៈកម្មាធិការនីមួយៗត្រូវរៀបចំឱ្យមានអង្គភាពជាក់លាក់ណាមួយនៃក្រសួងដែលជាប្រធានអនុគណៈកម្មាធិការ ដើម្បីធ្វើជាសេនាធិការ។

លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវផ្តល់ការគាំទ្រ និងធ្វើកិច្ចសហការជាមួយអង្គភាពដែលជាសេនាធិការឱ្យអនុគណៈកម្មាធិការនីមួយៗ ដើម្បីជួយដល់អនុគណៈកម្មាធិការ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៨.-**

អនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា៥ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ អង្គារ ៥ រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.**

**អភិសន្តិបណ្ឌិត ស សុខា**

<u>កន្លែងទទួល</u> ÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ